រដ្ឋបាលជលផល

Food and Agriculture Organization of the United Nations

This programme is funded by the European Union

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
រដ្ឋបាលជលផល

# សេចក្តីជូនព័ត៌មានរបស់រដ្ឋបាលជលផល ស្តីពី ការប្រមូលទិន្នន័យនៃការសិក្សាវាយតម្លៃផលចាប់ជលផលទឹកសាប ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

មន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផល ដោយមានការគាំទ្រថវិកាពីសហភាពអឺរ៉ុប និងគាំទ្របច្ចេកទេសពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) នឹងធ្វើការសិក្សាវាយតម្លៃផលចាប់ជលផលទឹកសាបនៅក្នុងភូមិរបស់អ្នក ចាប់ពី ខែធ្នូ ឆ្នាំ២០២០ នេះតទៅ។ គ្រួសារអ្នកនេសាទចំនួន ១៥គ្រួសារ នៅក្នុងភូមិរបស់អ្នក នឹងត្រូវជ្រើសរើសដើម្បីធ្វើការសម្ភាសអំពីផលចាប់ត្រី ផលចាប់វារីសត្វផ្សេងៗ សមត្ថភាពនេសាទ ការប្រើប្រាស់ឧបករណ៍នេសាទ និងទីតាំងនេសាទ ក្នុងកំឡុងពេល ៥ថ្ងៃ ជាប់ៗគ្នាកន្លងទៅ។ មន្ត្រីជលផល នឹងមកជួបសម្ភាសគ្រួសារអ្នកនេសាទទាំង ១៥ គ្រួសារនេះ ជារៀងរាល់ខែ។ ការសិក្សានេះផ្តោតលើអ្នកនេសាទ ពេញម៉ោង មិនពេញម៉ោង និងអ្នកនេសាទតាមរដូវកាល។

ការប្រមូលទិន្នន័យ នឹងអនុវត្តគ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា ដោយជ្រើសរើសយកចំនួន ៦០ភូមិ និងគ្រួសារអ្នកនេសាទ សរុបចំនួន ៩០០គ្រួសារ សម្រាប់ធ្វើការសិក្សានេះ។ ទិន្នន័យបានមកពីការសម្ភាស នឹងត្រូវប្រើប្រាស់សម្រាប់ប៉ាន់ប្រមាណផលចាប់ជលផលសរុបតាមប្រភេទ សមត្ថភាពនេសាទ ការលក់ដូរត្រី ផលចាប់តាមប្រភេទ ឧបករណ៍នេសាទ និងទីជម្រក។ ព័ត៌មានទាំងនេះជាជំនួយដល់រដ្ឋបាលជលផលក្នុងការវាយតម្លៃសារៈសំខាន់នៃជលផលទឹកសាបខ្នាតតូច ក្នុងការវាយតម្លៃសកម្មភាពសហគ្រប់គ្រងរបស់សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី និងធ្វើឱ្យប្រសើរឡើងនូវការកសាងផែនការ សម្រាប់រាជរដ្ឋាភិបាលក្នុងការគាំទ្រដល់អ្នកនេសាទ។

យើងខ្ញុំសូមស្នើសុំឱ្យមានការសហការល្អក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវអំពីសកម្មភាពនេសាទរបស់អ្នក។ យើងខ្ញុំសង្ឃឹមថា អ្នកទាំងអស់គ្នា នឹងចូលរួមសហការដើម្បីធ្វើឱ្យការសិក្សាវាយតម្លៃនេះ ទទួលបានជោគជ័យ និងរួមគ្នាលើកស្ទួយដល់និរន្តរភាពនៃមុខរបរចិញ្ចឹមជីវិតក្នុងវិស័យជលផល។

© IFReDI/FiA

Fisheries Administration

## ទំនាក់ទំនង៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)

*ផ្ទះលេខ៥ ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១*
*ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ*
*លេខទូរស័ព្ទ៖ (៨៥៥) ២៣ ២១៦ ៥៦៦*
*អ៊ីម៉ែល៖ FAO-KH@fao.org*
*គេហទំព័រ៖ www.fao.org/cambodia*

រដ្ឋបាលជលផល

*អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម*
*សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ*
*ប្រអប់សំបុត្រ៥៨២*
*លេខទូរស័ព្ទ៖ (៨៥៥) ២៣ ២១៥ ៤៧០*
*គេហទំព័រ៖ https://fia.maff.gov.kh/*

*ការបោះពុម្ពឯកសារនេះ ជាជំនួយរបស់សហភាពអឺរ៉ុប ហើយខ្លឹមសារនៅក្នុងឯកសារនេះ ជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផល និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*